

# ប្រកាស និងអនុក្រឹត្យ ស្តីពីច្បាប់ពន្ធដារ សម្រាប់ ឆ្នាំ ២០២៤

# ប្រកាស
# ស្តីពី
# ពន្ធកាត់ទុកលើថ្លៃឈ្នួល 10%

## អត្រាពន្ធ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវបានកំណត់ 10% នៃថ្លៃឈ្នួលអចលនទ្រព្យសរុប

## មូលដ្ឋានគិតប្រាក់ពន្ធ

1. 10% នៃថ្លៃឈ្នួលប្រចាំខែស្របតាមកិច្ចសន្យាជួល ឬកិច្ចព្រមព្រៀង ដោយផ្អែកលើតម្លៃទីផ្សារ
2. ថ្លៃឈ្នួលអចលនទ្រព្យសរុបដែលកម្មសិទ្ធិករ ឬសិទ្ធិវន្តបានទទួលពីអ្នកជួល ស្របតាមកិច្ចសន្យាជួល ឬកិច្ចព្រមព្រៀងជាមួយអ្នកជួលដោយផ្អែកលើតម្លៃទីផ្សារ

# ថ្លៃឈ្នួលលើកលែងពន្ធកាត់ទុក

1. ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់ស្ថាប័នរដ្ឋ
2. ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់កុងស៊ុលបរទេស ការទូត ឬអង្គការអន្តរជាតិ ឬភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃ
3. ប្រាក់ឈ្នួលពីការជួលអចលនទ្រព្យរបស់អង្គការ ឬសមាគន៍ណាមួយដែលត្រូវបានរៀបចំសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ និងមិនបានផ្តល់ផលប្រយោជន៍ដល់ឯកជន
4. ប្រាក់ឈ្នួលបានតម្កល់ទុកជាប្រាក់ធានា និងត្រូវសងត្រឡប់វិញពេលបញ្ចប់កិច្ចសន្យាជួល ឬកិច្ចព្រមពព្រៀង
5. ប្រាក់ឈ្នួលបានកាត់ទុករួចហើយ
6. ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់សហគ្រាសតាមរបបស្វ័យប្រកាសដែលបានគិតក្នុងប្រាក់ចំណូលជាប់ពន្ធហើយ
7. ឈ្នួលនៃអចលនទ្រព្យតិចជាង ៥០ ម៉ឺនរៀល





## កាតព្វកិច្ចរបស់កម្មសិទ្ធិករ ឬសិទ្ធិវន្ត

1. ចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធនៃទីតាំងអចលនទ្រព្យស្ថិតនៅក្នុងរយៈពេល 15 ថ្ងៃគិតចាប់ពីចុះកកិច្ចសន្យាជួល
2. ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល 15 ថ្ងៃបន្ទាប់ពីការឈប់ជួលដោយមានចុះកាលបរិច្ឆេទត្រឹមត្រូវ
3. ចេញឯកសារទទួលប្រាក់ជូនអ្នកជួលក្នុងពេលទទួលប្រាក់ឈ្នួលម្តងៗ
4. អ្នកជួលត្រូវមានកាតព្វកិច្ចបង្ហាញឯកសារទទួលប្រាក់ដែលកម្មសិទ្ធិករ ឬសិទ្ធិវន្តនិងត្រូវផ្តល់ពត៌មានផ្សេងៗ ករណីមានការស្នើសុំ



## ការបង់ប្រាក់ពន្ធ និងកាលបរិច្ឆេទ

1. កម្មសិទ្ធិករ ឬសិទ្ធិវន្ត ឬអ្នកតំណាង ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យជូនរដ្ឋបាលសារពើពន្ធតាមការកំណត់ដូចខាងក្រោម៖
   - ជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី 20 នៃខែបន្ទាប់ (ក្នុងករណញបង់ថ្លៃឈ្នួលរាល់ខែ)
   - យ៉ាងយឺតបំផុតត្រឹមថ្ងៃទី 20 នៃខែបន្ទាប់ដែលត្រូវធ្វើការទូទាត់ទៅតាមចំនួនទឹកប្រាក់សរុប ប្រសិនបើកិច្ចសន្យាមានការបង់ប្រាក់សរុបច្រើនខែ

# អនុក្រឹត្យ

# ស្តីពី

# ពន្ធប៉ាតង់

**SMALL**

## អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូចត្រូវបង់ប៉ាតង់ប្រចាំឆ្នាំចំនួន 400,000 រៀលក្នុងមួយឆ្នាំ

**Medium**

## អ្នកជាប់ពន្ធមធ្យម

អ្នកជាប់ពន្ធមធ្យមត្រូវបង់ប៉ាតង់ប្រចាំឆ្នាំចំនួន 1,200,000 រៀលក្នុងមួយឆ្នាំ

**BiG**

## អ្នកជាប់ពន្ធធំ

1. ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន 3,000,000 រៀលក្នុងមួយឆ្នាំ
2. ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន 5,000,000 រៀលក្នុងមួយឆ្នាំ ក្នុងករណីមានផលរបរលើសពី 10,000 លានរៀល
3. ក្នុងការណីចាប់ផ្តើមអាជីវកម្មបាន ៦ខែ ត្រូវបង់ពន្ធប៉ាតង់ពាក់កណ្តាលឆ្នាំ

# អនុក្រឹត្យ
# ស្តីពី
# កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ
# និងកម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ

## 1.កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធសម្រាប់និយោជិតនិវាសនជន ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | កម្រិប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ (គិតជារៀល) | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| 01 | ពី | 0 | ដល់ | 1,500,000 | 0% |
| 02 | ពី | 1,500,001 | ដល់ | 2,00,000 | 5% |
| 03 | ពី | 2,000,001 | ដល់ | 8,500,000 | 10% |
| 04 | ពី | 8,500,001 | ដល់ | 12,500,000 | 15% |
| 05 | | | លើសពី | 12,500,000 | 20% |

2. ទឹកប្រាក់កាត់បន្ថយ៖
   - កូនស្ថិតក្នុងបន្ទុកចំនួន 150,000 រៀល/ម្នាក់ក្នុងមួយខែ
   - សហព័ន្ធដែលធ្វើជាមេផ្ទះចំននួន 150,000 រៀល/ម្នាក់ក្នុងមួយខែ



## 2. កម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំនិងអត្រាប្រាក់ពន្ធសម្រាប់សហគ្រាសឯកបុគ្គល និចំណែកដែលត្រូវបែកចែកឲ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែមិនចាត់ទុកជានីតិបុគ្គល

| ល.រ | កម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ (គិតជារៀល) | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| 01 | ពី | 0 | ដល់ | 18,000,000 | 0% |
| 02 | ពី | 18,000,001 | ដល់ | 24,000,000 | 5% |
| 03 | ពី | 24,000,001 | ដល់ | 102,000,000 | 10% |
| 04 | ពី | 102,00,001 | ដល់ | 150,000,000 | 15% |
| 05 | | | លើសពី | 150,000,000 | 20% |

# ប្រកាស
# ស្តីពី
# ពន្ធលើផ្ទាំងផ្សព្វផ្សាយ



# ផ្ទាំងផ្សព្វផ្សាយ សំដៅដល់៖

បណ្ណកម្មសិទ្ធិ ស្លាក ឬផ្ទាំងដែលមានអក្សរគំនូរ និង/ឬរូបភាពជីវចល ឬអជីវចលសម្រាប់គោលបំណងផ្សព្វផ្សាយពាណិជ្ជកម្ម ដើម្បីធ្វើឲ្យអតិថិជន ឬសាធារណៈជនបានស្គាល់ផលិតផល សេវាកម្ម និងពត៌មានផ្សេងៗដែលពាក់ព័ន្ធនិងអាជីវកម្មរបស់អ្នកជាប់ពន្ធរួមមាន៖

| | |
|---|---|
| 1 | បណ្ណប្រកាសផ្សព្វផ្សាយធ្វើអំពីក្រដាសធម្មតា |
| 2 | បណ្ណប្រកាសផ្សព្វផ្សាយធ្វើអំពីកៅស៊ូ កំណាត់សំពត់ |
| 3 | ស្លាកអាជីវកម្មដ្ឋាន |
| 4 | ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពចល័តដែលភ្ជាប់ជាមួយបធ្យោបាយដឹកជញ្ជូន |
| 5 | ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពចល័តដែលនៅមួយកន្លែង |

# ការលើកលែងពន្ធ

ស្លាករបស់រដ្ឋ

ស្ថានទូតកុងស៊ុល ឬ អង្គការមិនមែនរដ្ឋាភិបាល

ផ្ទាំងផ្សព្វផ្សាយអប់រំមានប្រយោជន៍ដល់សង្គម




# ការដាក់លិខិតប្រកាសពន្ធ

ត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធទៅសាខាពន្ធដារដែលគ្រប់គ្រង

---

ចំពោះបណ្ណផ្សព្វផ្សាយធ្វើអំពីក្រដាស កៅស៊ូ កំណាត់សំពត់ ឬផ្សេងៗ ត្រូវបង់ពន្ធមុនផ្សព្វផ្សាយ

---

ក្នុងករណីចាប់ផ្តើមពី ៦ ខែចុងក្រោយត្រូងបង់ 50 % នៃប្រាក់ពន្ធត្រូវបង់

---

អ្នកជាប់ពន្ធធ្វើការផ្សព្វផ្សាយខ្លួនឯកឬជួលគេឲ្យផ្សព្វផ្សាយ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយ

---

អ្នកជាប់ពន្ធណាមួយដែលត្រូវបានគេជួលឲ្យធ្វើការផ្សព្វផ្សាយ អ្នកជាប់ពន្ធនោះត្រូវទទួលខុសត្រូវលើការដាក់លិខិតប្រកាស និងបង់ពន្ធប្រសិនបើផ្ទាំងផ្សព្វផ្សាយមិនទាន់បានបង់ពន្ធ

SK Law Office

# ប្រភេទផ្ទាំងផ្សព្វផ្សាយ និងអត្រាពន្ធ

1.ករណីស្លាកអាជីវកម្មដ្ឋាន ឬផ្ទាំងអក្សរ ឬរូបភាព មានជាប់ផ្ទាំងផ្សព្វផ្សាយរបស់សហគ្រាស ឬអាជីវកម្មដ្ឋានផ្សេង ការគណនាប្រាក់ពន្ធត្រូវធ្វើឡើងតាមប្រភេទអត្រា និងលក្ខខណ្ឌបន្ថែម ទៅតាមក្រឡាផ្ទៃជាក់ស្តែង

2. ចំពោះនិមិត្តសញ្ញា (ឡូហ្គោ) អាសយដ្ឋាន លេខទូរសព្ទ និងគេហទំព័រ ដែលមានអក្សរបរទេសនៅក្នុងផ្ទាំងផ្សព្វផ្សាយមិនត្រូវបានរាប់ចូលក្នុងលក្ខខណ្ឌបន្ថែមទេ

3.ភ្ជាប់មកជាមួយតារាងប្រភេទនៃផ្ទាំងផ្សព្វផ្សាយ និងអត្រាប្រាក់ពន្ធដែលមាននៅទំព័របន្ទាប់

SK Law Office

| លេខរៀង | ប្រភេទផ្ទាំងផ្សព្វផ្សាយ | អត្រាពន្ធ | | លក្ខខណ្ឌបន្ថែម |
|---|---|---|---|---|
| ១- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីក្រដាសធម្មតា ដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ៖ | | | | |
| ក | មានផ្ទៃក្រឡាមិនលើសពី ៤០ដេស៊ីម៉ែត្រការ៉េ | ៥០០៛/ទំព័រ | | បើមានអក្សរបរទេស ១ ៥០០៛/ទំព័រ |
| ខ | មានផ្ទៃក្រឡាលើសពី ៤០ដេស៊ីម៉ែត្រការ៉េ | ៧០០៛/ទំព័រ | | បើមានអក្សរបរទេស ២ ១០០៛/ទំព័រ |
| ២- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីកៅស៊ូ កំណាត់សំពត់ ឬវត្ថុផ្សេងៗ ដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ៖ | | | | |
| ក | មានផ្ទៃក្រឡាមិនលើសពី ៤០ដេស៊ីម៉ែត្រការ៉េ | ៧០០៛/ផ្ទាំង | | បើមានអក្សរបរទេស ២ ១០០៛/ផ្ទាំង |
| ខ | មានផ្ទៃក្រឡាលើសពី ៤០ ដល់ ១០០ដេស៊ីម៉ែត្រការ៉េ "បើលើសពី ១០០ដេស៊ីម៉ែត្រការ៉េ គិតជាផ្ទាំងអក្សរឬផ្ទាំងរូបភាព" | ១ ០០០៛/ផ្ទាំង | | បើមានអក្សរបរទេស ៣ ០០០៛/ផ្ទាំង |
| ៣- ស្លាកអាជីវកម្មដ្ឋាន ដូចមានចែងក្នុងវាក្យខណ្ឌ គ នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ៖ | | | | |
| ក | គ្មានពន្លឺលើកស្របជងផ្លូវ | ១០០៛/ម$^{២}$/ឆ្នាំ | ២០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ខ | គ្មានពន្លឺកែងជងផ្លូវ | ១៥០៛/ម$^{២}$/ឆ្នាំ | ៣០០៛ | |
| ៤- ស្លាកអាជីវកម្មដ្ឋាន ដូចមានចែងក្នុងវាក្យខណ្ឌ គ និងវាក្យខណ្ឌ ច នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ៖ | | | | |
| ក | មានពន្លឺលើកស្របជងផ្លូវ | ២០០៛/ម$^{២}$/ឆ្នាំ | ៤០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ខ | មានពន្លឺកែងជងផ្លូវ | ២៥០៛/ម$^{២}$/ឆ្នាំ | ៥០០៛ | |
| ៥- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងវាក្យខណ្ឌ ង នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ៖ | | | | |
| ក | គ្មានពន្លឺលើកស្របជងផ្លូវ | ៥០០៛/ម$^{២}$/ឆ្នាំ | ១ ០០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ខ | គ្មានពន្លឺកែងជងផ្លូវ | ៧០០៛/ម$^{២}$/ឆ្នាំ | ១ ៤០០៛ | |
| ៦- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងវាក្យខណ្ឌ ង និងវាក្យខណ្ឌ ច នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ៖ | | | | |
| ក | មានពន្លឺលើកស្របជងផ្លូវ | ៧០០៛/ម$^{២}$/ឆ្នាំ | ១ ៤០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ខ | មានពន្លឺកែងជងផ្លូវ | ១ ០០០៛/ម$^{២}$/ឆ្នាំ | ២ ០០០៛ | |
| ៧- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងវាក្យខណ្ឌ ឃ នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ៖ | | | | |
| ក | ដាក់ភ្ជាប់ តភ្ជាប់ ឬគូរផ្ទាល់នឹងមធ្យោបាយដឹកជញ្ជូននានា | ១ ៥០០៛/ម$^{២}$/ឆ្នាំ | ៣ ០០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |